**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា - CDRI**
**ការជំរាបជូនពីអធិបតីភាពរបស់**

# សម្តេច ហ៊ុន សែន

**នាយករដ្ឋមន្ត្រី នៃ រាជរដ្ឋាភិបាលកម្ពុជា**
**ដោយ**
**លោក Larry Strange នាយកប្រតិបត្តិ នៃ វិទ្យាស្ថាន CDRI**
**ក្នុងពិធីបើកអង្គសន្និសីទចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០០៧**
**ថ្ងៃទី ២២-២៣ ខែកុម្ភៈ ឆ្នាំ២០០៧ នៅសណ្ឋាគារ កាំបូឌីយ៉ាណា ភ្នំពេញ**

សូមគោរព សម្តេច **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា
សូមគោរព ឯកឧត្តម **ជា ចាន់តូ** ទេសាភិបាលនៃធនាគារជាតិនៃកម្ពុជា និង ប្រធានកិត្តិយសនៃក្រុមប្រឹក្សាភិបាល វិទ្យាស្ថាន CDRI
សូមគោរព ឯកឧត្តមបណ្ឌិត **ហង់ ជួន ណារ៉ុន** អគ្គលេខាធិការនៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ និង អគ្គលេខាធិការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ប្រធានក្រុមប្រឹក្សាភិបាលនៃ វិទ្យាស្ថាន CDRI
សូមគោរព អ្នកឧកញ៉ា **គិត ម៉េង** ប្រធានធនាគារអេអិនហ្សេតរ៉ូយ៉ាល់
សូមគោរព លោក **Dean Cleland** នាយកប្រតិបត្តិ នៃធនាគារអេអិនហ្សេតរ៉ូយ៉ាល់
សូមគោរព ឯកឧត្តម លោកជំទាវ លោក លោកស្រី និងប្រិយមិត្ត ជាភ្ញៀវកិត្តិយសទាំងអស់

ក្នុងឋានៈជា នាយកប្រតិបត្តិនៃ វិទ្យាស្ថាន CDRI ខ្ញុំមានសេចក្តីរីករាយជាពន្លឹក សូមស្វាគមន៍ ឯកឧត្តម លោកជំទាវ លោក លោកស្រី និងប្រិយមិត្ត ជាភ្ញៀវកិត្តិយសទាំងអស់ ដែលបានអញ្ជើញមកចូលរួមក្នុងទិវាបើកសន្និសីទចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០០៧ និងសូមជំរាបជូនពីអធិបតីភាព និងការថ្លែងសុន្ទរកថាគន្លឹះ របស់សម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** ក្នុងទិវាដ៏មហោឡារិកនេះ ។

នៅពេលខ្ញុំបានជួបសវនាការជាមួយសម្តេចនាយករដ្ឋមន្ត្រី នៅខែតុលា ឆ្នាំមុន ដើម្បីរាយការណ៍ពីការងាររបស់វិទ្យាស្ថាន CDRI និងស្នើសុំមតិណែនាំ និងការគាំទ្រពីសម្តេចនាយករដ្ឋមន្ត្រី ដល់គំរោងរៀបចំសន្និសីទចក្ខុវិស័យ ប្រចាំឆ្នាំ ខ្ញុំមានអំណរគុណជាពន្លឹក ចំពោះការអនុគ្រោះចំនួនពីរយ៉ាងរបស់សម្តេច ។ ទីមួយ គឺការគាំទ្រភ្លាម១យ៉ាងកក់ក្តៅដល់គោលគំនិតរៀបចំសន្និសីទចក្ខុវិស័យ ដែលត្រូវអញ្ជើញអ្នកដឹកនាំ ពីគ្រប់មជ្ឈដ្ឋាននៅកម្ពុជាមកជួបជុំគ្នា ដើម្បីផ្លាស់ប្តូរមតិ និង ពិភាក្សាពីយុទ្ធសាស្ត្រសំរាប់ការអភិវឌ្ឍន៍ និងវិបុលភាពនៅប្រទេសកម្ពុជា។ បន្ទាប់មក គឺការគាំទ្រយ៉ាងខ្លាំងក្លាដល់ ភាពជាដៃគូថ្មីមួយរវាង វិទ្យាស្ថាន CDRI ដែលជាស្ថាប័នស្រាវ

ស្រាវជ្រាវឯករាជ្យ និងនាំមុខគេខាងគោលនយោបាយអភិវឌ្ឍន៍ ហើយនិង ធនាគារអេអិនហ្សេតរ៉ូយ៉ាល់ ដែលជាតួអង្គថ្មីដ៏មានសន្ទុះនៅក្នុងវិស័យសេវាកម្មហិរញ្ញវត្ថុនៅកម្ពុជា ហើយស្ថាប័នទាំងពីរនេះ មានការប្តេជ្ញាចិត្តដូចគ្នា ដើម្បីចូលរួមចំណែកកសាងអនាគតប្រទេសកម្ពុជា។ នាឱកាសសវនាការនោះ ខ្ញុំមានការដឹងគុណជាពិសេសដល់សម្តេច នាយករដ្ឋមន្ត្រីចំពោះសេចក្តីបញ្ជាក់ដ៏រឹងប៉ឹងដល់រូបខ្ញុំ ហើយបន្ទាប់មកទៀតដល់ប្រព័ន្ធផ្សព្វផ្សាយកម្ពុជាស្តីពីការ គាំទ្ររបស់សម្តេច ចំពោះឯករាជភាព អព្យាក្រឹតភាព និងការប្តេជ្ញាចិត្តរបស់វិទ្យាស្ថាន CDRI ដើម្បីកសាងគុណភាពឱ្យបានប្រសើរបំផុត នៃការស្រាវជ្រាវខាងគោលនយោបាយដែលមានប្រយោជន៍ច្រើនណាស់ដល់អ្នកពាក់ព័ន្ធសំខាន់ៗក្នុងការអភិវឌ្ឍន៍ប្រទេសកម្ពុជា ពោលគឺ រដ្ឋាភិបាល វិស័យឯកជន សហគមន៍អ្នកស្រាវជ្រាវសង្គមស៊ីវិល និង អង្គការអភិវឌ្ឍន៍អន្តរជាតិ និងចំពោះការប្រឹងប្រែងកសាងសមត្ថភាពអ្នកស្រាវជ្រាវកម្ពុជាដែលជាទុនវិនិយោគមួយដ៏សំខាន់សំរាប់អនាគតប្រទេសកម្ពុជា ។ ការគាំទ្ររបស់សម្តេច ចំពោះឯករាជភាពរបស់យើងខ្ញុំមានសារៈសំខាន់បំផុតសំរាប់ភាពគួរជឿទុកចិត្ត និង ឥទ្ធិពលនៃការងាររបស់យើងខ្ញុំនៅក្នុងមជ្ឈដ្ឋានអ្នកគាំទ្រ ដូចមានអ្នកតំណាងនៅទីនេះស្រាប់ ។ ក្រុមប្រឹក្សាភិបាល ថ្នាក់គ្រប់គ្រង និងបុគ្គលិកវិទ្យាស្ថាន CDRI ទាំងអស់ សូមអរគុណជាពន្លឺកចំពោះសម្តេចនាយករដ្ឋមន្ត្រី ។

## សម្តេចនាយករដ្ឋមន្ត្រី ឯកឧត្តម លោកជំទាវ និងភ្ញៀវកិត្តិយសជាទីគោរព

នៅពេលខ្ញុំមើលឃើញនៅក្នុងបន្ទប់សន្និសីទនេះ នូវសមាសភាពដ៏ឆ្នើម និងអ្នកដឹកនាំមកពីគ្រប់វិស័យនៅកម្ពុជា ខ្ញុំមានជំនឿយ៉ាងមុតមាំទៅលើបាវចនានៃសន្និសីទចក្ខុវិស័យ ដែលថា "**អនាគតស្ថិតនៅក្នុងដៃរបស់យើង**" ពីព្រោះជាការពិតណាស់ ជោគជ័យនៃការអភិវឌ្ឍន៍ និង វិបុលភាពរួមនៅកម្ពុជា ត្រូវពឹងផ្អែកលើសមត្ថភាព ការតាំងចិត្ត និងភាពឧស្សាហ៍ព្យាយាមរបស់អ្នកចូលរួមនៅទីនេះ ដែលត្រូវធ្វើការរួមគ្នាដើម្បីចាប់យកឱកាសល្អ និងដោះស្រាយបញ្ហាប្រឈមនានាចំពោះប្រទេសកម្ពុជា ហើយនៅថ្ងៃស្អែក យើងនឹងពិនិត្យ ស្រាវជ្រាវពីបញ្ហាសំខាន់ៗជាច្រើន ដែលជាកត្តាកំណត់លើអនាគតនេះ។ ប៉ុន្តែនៅព្រឹកនេះ ដើម្បីបំផុសគំនិតឡើង និងផ្តល់ជាបរិបទមួយសំរាប់ការពិភាក្សានៅថ្ងៃស្អែក យើងទាំងអស់គ្នាមានភព្វសំណាង ជាពិសេសដោយបានទទួលមតិណែនាំដោយផ្ទាល់ពីសម្តេច **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា។ ខ្ញុំមានកិត្តិយស និងសេចក្តីរីករាយជាអនេក តាងនាមអោយ វិទ្យាស្ថាន CDRI និង ធនាគារ អេអិនហ្សេតរ៉ូយ៉ាល់ សូមគោរពអញ្ជើញ សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ថ្លែងសុន្ទរកថាគន្លឹះ បើកអង្គសន្និសីទចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០០៧ ក្រោមប្រធានបទថា "**ចក្ខុវិស័យកម្ពុជា ឆ្នាំ២០០៧ : កាលានុវត្តភាព ដើម្បីកំណើន ការអភិវឌ្ឍន៍ និងវិបុលភាពរួម**" ។

សូមអរគុណ